ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

## សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា

នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០០៨

សូមគោរព :

- លោកជំទាវ ទេសាភិបាលរង
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកជួបជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ក្នុងឱកាសប្រារព្ធធ្វើសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ របស់យើង បន្ទាប់ពីប្រទេសកម្ពុជាយើងបានបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅនេះ ។

ខ្ញុំសូមស្វាគមន៍ យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលជាតំណាងនាយកដ្ឋាន នានានៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតរបស់យើង នាពេលនេះ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើងទាំងអស់គ្នា ដែលបានរួមចំណែកកសាងសមិទ្ធផលទាំងឡាយ ជូនធនាគារជាតិនៃកម្ពុជា កន្លងមក *ពោលគឺ* បានកសាងប្រព័ន្ធធនាគារយើងឱ្យមានការរីកចម្រើន មានសុវត្ថិភាព មានសុខភាពរឹងមាំ និងទទួលបានការជឿទុកចិត្តបន្ថែមទៀតពីសាធារណជនទូទៅ រាជរដ្ឋាភិបាល និងពីសហគមន៍អន្តរជាតិ ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

គោលបំណងសំខាន់នៃការរៀបចំសន្និបាតរបស់យើងថ្ងៃនេះ គឺដើម្បីផ្សព្វផ្សាយពី :

១- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជានៅឆមាសទី១ ឆ្នាំ២០០៨

២- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆមាសទី១ ឆ្នាំ២០០៨ ។

## I- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

នៅឆមាសទី១ ឆ្នាំ២០០៨ នេះ ពិភពលោកយើងប្រឈមមុខនឹងបញ្ហាធំៗមួយចំនួន ដូចជា *១)*- វិបត្តិឥណទាននិក្ខេប (Mortgage loan crisis) *២)*- ការធ្លាក់ចុះនៃប្រាក់ដុល្លារអាមេរិក ឬវិបត្តិសេដ្ឋកិច្ចអាមេរិក *៣)*- ប្រេងឥន្ធនៈឡើងថ្លៃ *៤)* - គ្រោះធម្មជាតិក្នុងតំបន់ *៥)* - ការឡើងថ្លៃនៃគ្រឿងឧបភោគ-បរិភោគ ឬវិបត្តិអង្ករ និង *៦)* - បញ្ហាអតិផរណាដែលជាកង្វល់រួមរបស់កម្ពុជាយើងផង តំបន់ផង និងរបស់ពិភពលោកទាំងមូលផង ។

ដោយសារកត្តាទាំងនេះ ទើបនៅឆ្នាំ២០០៨នេះ តាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា សេដ្ឋកិច្ចពិភពលោកមាននិន្នាការថយចុះ ដោយអត្រាកំណើនត្រឹមតែ ៤.១% ធៀបនឹងអត្រា ៥% នៅឆ្នាំ២០០៧ ។ អត្រាកំណើនសេដ្ឋកិច្ចអាមេរិកនឹងកើនក្នុងកម្រិត ១.៣% សហភាពអឺរ៉ុប ១.៧% ប្រទេសជប៉ុន ១.៥% ចិន ៩.៨% និងប្រទេសឥណ្ឌា ៨% ។ បើតាមការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំណើនសេដ្ឋកិច្ចនៃក្រុមប្រទេសអាស៊ាន ក៏បានបង្ហាញនិន្នាការថយចុះក្នុងកំរិត ៥.៧% ធៀបអត្រានឹង ៦.៥% នៅឆ្នាំ២០០៧ ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានស្ថានភាពល្អប្រសើរក្នុងអត្រាកំណើនពីរខ្ទង់ ដោយផលិតផលក្នុងស្រុកដុលមានកំណើន ១៣.១% នៅឆ្នាំ២០០៥ ១០.៨% នៅឆ្នាំ២០០៦ និង ១០.១% នៅឆ្នាំ២០០៧ ហើយនៅឆ្នាំ២០០៨នេះ តាមការព្យាករណ៍ដោយប្រុងប្រយ័ត្នរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សេដ្ឋកិច្ចកម្ពុជា នឹងមានអត្រាកំណើន ៧.២% ដោយសារតែសេដ្ឋកិច្ចកម្ពុជាទទួលរងនូវផលប៉ះពាល់ពីខាងក្រៅ ប៉ុន្តែបានប៉ះប៉ូវមកវិញនូវកំណើននៃវិស័យទេសចរ សេវាកម្ម និងកសិកម្ម ខាងវិស័យកាត់ដេរ និងសំណង់ផងដែរ ។

ចំពោះបញ្ហាអតិផរណា បន្ទាប់ពីរាជរដ្ឋាភិបាលបានចាត់វិធានការជាកញ្ចប់រួចមក អត្រាអតិផរណាប្រចាំឆ្នាំត្រូវបានព្យាករណ៍អាចនឹងមានកម្រិត ២០% ដោយសារប្រសិទ្ធភាពនៃវិធានការណ៍ជាកញ្ចប់របស់រាជរដ្ឋាភិបាល ទោះបីជាកម្រិតអតិផរណាកាលពីដើមឆ្នាំ កើនឡើងគួរឱ្យកត់សំគាល់ក៏ដោយ ។

## II- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆមាសទី១ ឆ្នាំ២០០៨

ក្នុងឆមាសទី១ ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ បានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។

### លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ជាលទ្ធផល នៅឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចសមិទ្ធផលសំខាន់ៗ ដូចតទៅ :

ជារួមស្ថានភាពម៉ាក្រូសេដ្ឋកិច្ច នៅតែរក្សាភាពល្អប្រសើរនៃកំណើនជាប់ជាប្រចាំ ទោះបីជាអត្រាកំណើនមានការថយចុះបន្តិច និងទទួលរងនូវផលប៉ះពាល់ពីខាងក្រៅ ដែលធ្វើឱ្យអត្រាអតិផរណាកើនឡើងគួរឱ្យកត់សំគាល់

បន្តិចក៏ដោយ ក៏អត្រាប្តូរប្រាក់ និងតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក មានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់រៀលបានឡើងថ្លៃប្រមាណ ០.៦% ក្នុងឆមាសទី១ ឆ្នាំ២០០៨ ។ ស្ថិរភាពនៃតម្លៃប្រាក់រៀល បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងទំនុកចិត្តរបស់សាធារណជន អាជីវករ និងវិនិយោគិន ចំពោះទស្សនវិស័យវិជ្ជមាននៃសេដ្ឋកិច្ចកម្ពុជា តាមរយៈការកាត់បន្ថយហានិភ័យផ្សេងៗ ។

ចំពោះការគ្រប់គ្រងទុនបម្រុងអន្តរជាតិ យើងផ្អែកលើមូលដ្ឋានប្រុងប្រយ័ត្ន និងសុវត្ថិភាពសាច់ប្រាក់ ។ គិតមកត្រឹមឆមាសទី១ ឆ្នាំ២០០៨ ទុនបម្រុងអន្តរជាតិវិនិយោគរបស់យើងបានកើនឡើងជាង ២.២០០ លានដុល្លារ ហើយដែលអាចធានាបាននូវការនាំចូលចំនួន ៣ ខែ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងវិស័យធនាគារ ធនាគារជាតិនៃកម្ពុជាបានអនុវត្តកម្មវិធីកំណែទម្រង់ដែលមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍនវិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ហើយទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ដូចខាងក្រោម :

១)_ប្រព័ន្ធធនាគារ : មានការរីកចម្រើនទាំងវិសាលភាព និងទំហំសកម្មភាព ហើយបានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងទទួលបានការគាំទ្រ និងជំនឿទុកចិត្តពីសាធារណជនទូទៅ ។ ចំពោះផ្នែកវិសាលភាព ធនាគារពាណិជ្ជកើនដល់ចំនួន២២ តាមរយៈការចូលមកវិនិយោគរបស់វិនិយោគិនកូរ៉េ និងជប៉ុន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានចំនួន១៧ ។ ចំណែកឯទំហំសកម្មភាពវិញ ទ្រព្យសកម្មសរុបកើនឡើង ២០% ប្រាក់បញ្ញើកើន ២៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០០៧ កើន ១២% និង ឥណទានធនាគារពាណិជ្ជចំពោះវិស័យឯកជនកើន ៨៣% ធៀបនឹងឆមាសទី១ ឆ្នាំ២០០៨ នេះ កើន ៥២% ។

២)_វិស័យមីក្រូហិរញ្ញវត្ថុ : មានការរីកចម្រើនយ៉ាងឆាប់រហ័ស និងមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ហើយទទួលបានការគាំទ្រពីមជ្ឈដ្ឋានក្នុងនិងក្រៅប្រទេសថា ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០០៨ នេះ ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនដល់ ៨៥១ ពាន់ លានរៀល គឺកើនចំនួន ៧៣% និងមានអតិថិជនរហូតដល់ ៦៧២.៧២៥នាក់ ធៀបនឹងឆ្នាំ២០០៧ ចំនួន ៦២៤.០៤៨នាក់ បានទទួលឥណទាន ចំនួន ៦៤១ ពាន់លានរៀល និងបានប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុផ្សេងទៀត ។ ភាពជឿនលឿននេះ បញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជា មានការយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទានកាន់តែប្រសើរឡើង ។

៣)_ការងារត្រួតពិនិត្យធនាគារ : ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធធនាគារទាំងមូល ធនាគារជាតិនៃកម្ពុជា បានពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារជាប់ជាប្រចាំ តាមរយៈការដាក់កម្មវិធីចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ ដើម្បីជួយធនាគារពាណិជ្ជឱ្យពង្រឹងការគ្រប់គ្រង និងការងារសវនកម្មផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងឱ្យធនាគារទាំងនេះធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាសាធារណៈដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជន មកលើប្រព័ន្ធធនាគារ ។ នៅដើមឆ្នាំ២០០៨ នេះ យើងបង្កើនដើមទុន

កាតព្វកិច្ចពី៨% ទៅ ១៦% ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងអតិផរណា និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅលើកកំពស់ជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើង ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

យើងបានជំរុញការអនុវត្តប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រយោជន៍ដើម្បីកាត់បន្ថយហានិភ័យឥណទាន ជំរុញការ ផ្តល់ប្រាក់កម្ចីដល់វិស័យឯកជន និងទទួលបានព័ត៌មានឥណទានជាអវិជ្ជមានពិតប្រាកដ ។ ចំពោះការត្រួតពិនិត្យលើឯកសារ យើងក៏បានអនុវត្តនូវកម្មវិធីកុំព្យូទ័រកូប្រា (COBRA) ដើម្បីឱ្យការត្រួតពិនិត្យលើឯកសារកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពសំរាប់ការវិភាគ និងវាយតម្លៃស្ថានភាពធនាគារឱ្យកាន់តែសុក្រឹតឡើង ។ នៅឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយ *"របាយការណ៍ត្រួតពិនិត្យធនាគារពាណិជ្ជ ប្រចាំឆ្នាំ២០០៧"* ប្រយោជន៍ដើម្បីឱ្យអ្នកដាក់ប្រាក់បញ្ញើ សាធារណជនទូទៅបានស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីប្រព័ន្ធធនាគារនៅកម្ពុជា ។

**៤).ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង :** ធនាគារជាតិនៃកម្ពុជា បានពង្រឹងប្រតិបត្តិការរបស់ខ្លួនទាំងនៅទីស្នាក់ការកណ្តាល និងសាខាខេត្ត-ក្រុង ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលការបង់ពន្ធគ្រប់ប្រភេទ គ្រប់គ្រងគណនីរបស់ស្ថាប័នរដ្ឋ ចាត់ចែងសំរួលសាច់ប្រាក់តាមរយៈការបង្វែរសាច់ប្រាក់របស់រតនាគារជាតិ និងបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ។

**៥).អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា បន្ទាប់ពីច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្មបានអនុម័ត ដើម្បីរួមចំណែកជាមួយសហគមន៍ជាតិ-អន្តរជាតិ ការពារទប់ស្កាត់ និងប្រឆាំងរាល់បទល្មើសទាក់ទងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**៦).ការពង្រឹងរចនាសម្ព័ន្ធប្រាក់រៀល :** ដោយមានការអនុញ្ញាតិពីរាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយ និងដាក់ឱ្យចរាចរនូវធនប័ត្រប្រភេទ ២.០០០ រៀល និង ២០.០០០ រៀល ដើម្បីជួយសំរួលដល់ប្រតិបត្តិការទូទាត់ សន្សំ និងប្តូររបស់ប្រជាជនកម្ពុជាក្នុងការប្រកបមុខរបរអាជីវកម្ម ។

**៧).ការពង្រឹងក្របខ័ណ្ឌច្បាប់ :** យើងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីភតិសន្យា ។ ច្បាប់នេះគឺជាមូលដ្ឋានគតិយុត្តមួយសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា និងសម្រាប់កៀងគរប្រភពទុនរយៈពេលវែងទៅពង្រីកគម្រោងវិនិយោគ ប្រកបដោយចិរភាព ។ ទន្ទឹមនេះ យើងបានបន្តកែលំអវិធានការប្រុងប្រយ័ត្ននិងបទប្បញ្ញត្តិមួយចំនួន បានធ្វើចំណាត់ថ្នាក់ឥណទានតាមវិស័យ និងតាមកម្រិតហានិភ័យ ដើម្បីពង្រឹងប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយរលូន មានសុវត្ថិភាព និងប្រសិទ្ធភាព ឆ្ពោះទៅរកការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

៨).ការពង្រឹងអភិបាលកិច្ច : ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ច តាមរយៈប្រកាសស្តីពីគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា និងប្រកាសស្តីពីក្រមសីលធមិសម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ។ នៅក្នុងឆមាសទី១ ឆ្នាំ២០០៨នេះ មន្ត្រីជំនាញយើងបានចុះធ្វើសវនកម្មនៅនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគណនេយ្យ និងសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត ខេត្តកោះកុង និងខេត្តកំពង់ឆ្នាំង ដោយមន្ត្រីអធិការកិច្ចរបស់យើងក៏បានចុះឆ្មក់ត្រួតពិនិត្យសាខាធនាគារជាតិនៃកម្ពុជាចំនួន៤ ដើម្បីធានាសុវត្ថិភាពឃ្លាំង និងគ្រប់គ្រងសាច់ប្រាក់ផងដែរ ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

៩).ចំពោះកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិវិញ : នៅឆមាសទី១ ឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជា មានកិច្ចសហប្រតិបត្តិការជាមួយ :

មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានកោតសសើរ និងវាយតម្លៃជារួមថា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានស្ថិរភាពល្អ ទោះបីជាមានកម្រិតអតិផរណាខ្ពស់បន្តិចក៏ដោយ ។ IMF បានបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងប្រសិទ្ធភាពការត្រួតពិនិត្យធនាគារថែមទៀត ។

ក្រុមប្រទេសអាស៊ាន (ASEAN) នៅដើមខែមេសា ឆ្នាំ២០០៨ នេះ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១២ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៤ នៅទីក្រុងដាណាំង ប្រទេសវៀតណាម ដើម្បីពិនិត្យការអនុវត្តចក្ខុវិស័យសហគមន៍អាស៊ាន (AEC) ដែលមានបំណងប្រែក្លាយតំបន់អាស៊ានឱ្យទៅជាតំបន់ដែលមានទីផ្សាររួមមួយ ផលិតផលតែមួយ និងមានចលនាទំនិញ សេវាកម្ម ការវិនិយោគ និងចលនាដើមទុនដោយសេរីនៅឆ្នាំ២០១៥ ។

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) : ធនាគារជាតិនៃកម្ពុជា បានដើរតួនាទីស្នូលក្នុងការអនុវត្តអនុកម្មវិធីទី១ ចប់ដោយជោគជ័យ និងបន្តសហការអនុវត្តគម្រោងកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទី២ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ។

មជ្ឈមណ្ឌល **SEACEN** : គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមសន្និសីទលើកទី៤៣ ស្តីពីការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល SEACEN នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី និងចូលរួមកិច្ចប្រជុំគណៈកម្មការ SEACEN លើកទី៦ (Exco) នៅខេត្តភូកេត ប្រទេសថៃ ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយ SEACEN ក្នុងការរៀបចំសិក្ខាសាលា ស្តីពីការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង នៅខេត្តសៀមរាប កាលពីខែ ឧសភា ឆ្នាំ២០០៨ ដើម្បីពង្រឹងការបណ្តុះបណ្តាលធនធានមនុស្ស ។

ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APG) ធនាគារជាតិនៃកម្ពុជាបានចូលរួមមហាសន្និបាតប្រចាំឆ្នាំ២០០៨ នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី និងសហការជាមួយ Austrac និងធនាគារពិភពលោក រៀបចំសិក្ខាសាលាចំនួន៣ដង នៅកម្ពុជា ដើម្បីស្វែងយល់ពីប្រតិបត្តិការសង្ស័យ ។

សមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA) : ធនាគារជាតិនៃកម្ពុជា បានចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី១៦ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី៥៤ នៅប្រទេសវៀតណាម ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល ផ្លាស់ប្តូរបច្ចេកទេសក្នុងការត្រួតពិនិត្យស្ថាប័នមីក្រូហិរញ្ញវត្ថុ និងការផ្តល់ឥណទានកសិកម្មជនបទ ។

ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីវិញ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ ធនាគារកណ្តាលវៀតណាម ធនាគារកណ្តាលឡាវ ធនាគារកណ្តាលលុចហ្សំបួរ ធនាគារកណ្តាលប៊ែលហ្ស៊ិក ធនាគារកណ្តាលអាឡឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ានមួយចំនួនទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនាគារកណ្តាល និងការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់យើង ។

លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

សរុបមក សមិទ្ធផលទាំងនេះ កើតចេញពីការខិតខំប្រឹងប្រែងរួម ដោយប្រើប្រាស់កម្លាំងសរុបរបស់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នា ។ ដើម្បីជ្រាបពីសមិទ្ធផលលំអិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកធ្វើឱ្យធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅពេញរយៈពេលមួយថ្ងៃ សូម លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំត្រងត្រាប់ស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ សំរាប់អនុវត្តឱ្យបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ~~និងបដិភាណៈ~~កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនេះ សូមឱ្យអង្គសន្និបាតរបស់យើងថ្ងៃនេះដំណើរការប្រកបដោយជោគជ័យ ។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**